មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លេខ: 00506 /13 /ម.ស.ម.ក/

សូមគោរពជូន
លោកជំទាវ យ៉ឹងឡាក់ ស៊ីណាត៉ាត្រា
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃឡង់ដ៍

កម្មវត្ថុ៖ សូមជួយពិនិត្យ នឹងអន្តរាគមន៍ ពាក់ព័ន្ធករណីបាញ់សម្លាប់ ជាបន្តបន្ទាប់លើប្រជាពលរដ្ឋខ្មែរលើទឹកដីថៃ និងកង្វះការស៊ើបអង្កេត។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សម្តែងនូវក្តីបារម្ភយ៉ាងខ្លាំងចំពោះការបាញ់ប្រហារជាបន្តបន្ទាប់លើជនស៊ីវិលកម្ពុជាក្នុងទឹកដីថៃ ដែលបានបណ្តាលឲ្យមានការស្លាប់ និងរងរបួសរាប់មិនអស់។ នៅឆ្នាំ២០១២ បានបង្ហាញការកើនឡើងគួរឲ្យតក់ស្លុតនូវចំនួននៃការវាយប្រហារដែលបានកត់ត្រា៖ ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ រាយការណ៍ថា មានជនស៊ីវិលខ្មែរ៤៥នាក់ត្រូវបានបាញ់សម្លាប់ដោយទាហានថៃ ក្នុងទឹកដីប្រទេសថៃ នៅក្នុងអំឡុងឆ្នាំ២០១២ ដែលចំនួននេះមានការកើនឡើងបីដងបើប្រៀបធៀបតួលេខឆ្នាំ២០១១ (ស្លាប់១៥នាក់)។ រហូតមកដល់ឆ្នាំ២០១៣នេះ ប្រជាពលរដ្ឋខ្មែរចំនួន៦នាក់ បានត្រូវរាយការណ៍មកថាត្រូវបានគេបាញ់សម្លាប់ហើយមានអ្នករងរបួស ឬអ្នកកំពុងតែបាត់ខ្លួនជាច្រើននាក់ទៀត។

ការបាញ់ប្រហារលើជនស៊ីវិលកម្ពុជាដែលបណ្តាលឲ្យស្លាប់ ឬប៉ះពាល់ដល់រាងកាយដ៏ធ្ងន់ធ្ងរ ជាសកម្មភាពខុសច្បាប់ និងជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនរងគ្រោះ។ ប្រទេសថៃគឺជាភាគីមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.ព.ស.អ") ដែលខ្លួនយល់ព្រមកាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៦ ហេតុដូចនេះប្រទេសថៃត្រូវចងជាភាគពួកិច្ចតាមផ្លូវច្បាប់ដោយបទប្បញ្ញត្តិទាំងនោះ។ មាត្រា៦ នៃ ក.ព.ស.អ ធានានូវសិទ្ធិរស់រានមានជីវិត ខណៈដែលមាត្រា៧ ចែងថា គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឲ្យថោកទាបឡើយ។ មាត្រា៨ ចែងថា មិនអនុញ្ញាតមានបដិប្បញ្ញត្តិនឹងមាត្រា៦ និងមាត្រា៧ឡើយ។ ម្យ៉ាងវិញទៀត មាត្រា២ ចងរដ្ឋហត្ថលេខីនានាឲ្យគោរព និងធានានូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុង ក.ព.ស.អ <u>លើបុគ្គលគ្រប់រូបដែលស្ថិតក្នុងដែនដីរបស់ខ្លួន និងស្ថិតក្រោមយុត្តាធិការរបស់ខ្លួន</u> ដែលរាប់បញ្ចូលទាំងជនស៊ីវិលកម្ពុជាផង ដែលស្ថិតក្នុងទឹកដីប្រទេសថៃ ទោះជាស្របច្បាប់ ឬពុំស្របច្បាប់ក្តី។ ប្រទេសថៃក៏ជាភាគីមួយនៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬអំពើធ្វើឲ្យអាប់ឱនដទៃទៀត ដែលមាត្រា១ ផ្តល់និយម

ន័យអំពើនៃការធ្វើទារុណកម្ម ហើយមាត្រា២ ចែងថា អំពើនៃការធ្វើទារុណកម្មមិនអាចធ្វើយុត្តិកម្មបានទេ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ ការបាញ់ប្រហារលើជនស៊ីវិលកម្ពុជា រំលោភបំពានលើសិទ្ធិទាំងអស់នេះ ដែលប្រទេសថៃបានអនុម័តជាផ្លូវការ ហើយខ្លួនត្រូវគោរពតាមច្បាប់។

ម.ស.ម.ក ធ្វើការកត់សម្គាល់តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសថៃ ក៏ដូចជា បទដ្ឋានអន្តរជាតិ ឃើញថាការប្រើប្រាស់កម្លាំងបង្ហិនដែលអាចបណ្តាលឲ្យស្លាប់ និងកាំភ្លើង គឺត្រូវផ្តល់យុត្តិកម្មបាន តែក្នុងករណីប្រើប្រាស់ប្រឆាំងនឹងអំពើគំរាមសម្លាប់ដ៏ធ្ងន់ធ្ងរ ឬការបង្ករបួសធ្ងន់ធ្ងរក្នុងពេលស្របពេលគ្នា និងជាក់ស្តែង ឬដើម្បីបង្ការនូវការកើតមានបទល្មើសធ្ងន់ធ្ងរជាក់លាក់ដែលពាក់ព័ន្ធនឹងការគំរាមកំហែង ឬដើម្បីចាប់ខ្លួនបុគ្គលណាដែលនឹងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ដែលអាចនិយាយម្យ៉ាងទៀតថាជាកិច្ចការពារខ្លួន។ បន្ថែមពីនេះ ការប្រើប្រាស់កម្លាំងបង្ហិនដែលអាចបណ្តាលឲ្យស្លាប់ អាចត្រូវគេប្រើតែក្នុងវិធានការចុងក្រោយបង្អស់ និងត្រូវតែមានសមាមាត្រដើម្បីអនុលោមតាមគោលបំណងច្បាប់។ ម.ស.ម.ក លើកឡើងថា ដោយសារតែអ្នកស្លាប់ គឺជាជនស៊ីវិលដែលគ្មានអាវុធក្នុងដៃ ដែលស្ថិតនៅក្នុងទឹកដីនៃប្រទេសថៃ ខណៈធ្វើការកាប់ឈើ ហើយដែលពុំមានចំណុចណាដែលធ្វើការគំរាមកំហែងពិតប្រាកដ និងក្នុងពេលស្របគ្នាចំពោះបុគ្គលណាម្នាក់នោះ ការបាញ់ប្រហារបែបនេះ មិនអាចផ្តល់ហេតុផលត្រឹមត្រូវ ថាជាកិច្ចការពារខ្លួននោះទេ ដោយសារតែមានការសម្លាប់ក្រៅប្រព័ន្ធច្បាប់ និងអំពើមនុស្សឃាតតាមអំពើចិត្តយ៉ាងច្រើន ហើយក៏មិនអាចត្រូវបានចាត់ទុកថាជាវិធានការចុងក្រោយឬសមាមាត្រនោះទេ។

រហូតមកទល់ពេលនេះ ម.ស.ម.ក មិនទាន់ឃើញនូវភស្តុតាងណាមួយពីសំណាក់អាជ្ញាធរអនុវត្តច្បាប់របស់ប្រទេសថៃ ឬក៏គណៈកម្មការជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សរបស់ប្រទេសថៃ ចាត់វិធានការណាមួយដើម្បីស៊ើបអង្កេតនូវអំពើឃាតកម្ម និងការប៉ុនប៉ងមនុស្សឃាតលើប្រជាពលរដ្ឋខ្មែរនោះឡើយ។ ភាពអសកម្មនេះ មិនត្រឹមតែជាការរំលោភបំពានដ៏ធ្ងន់ធ្ងរលើភារៈកិច្ចក្នុងការស៊ើបអង្កេតករណីរំលោភបំពានសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏បង្ហាញឲ្យឃើញពីកង្វះការទទួលខុសត្រូវទាំងស្រុងលើវិធានការចំពោះចារី ប្រសិនបើពុំមានការដាក់ពិន័យនោះទេ។ ប្រាកដណាស់ និទណ្ឌភាពទាំងស្រុងបែបនេះ គឺជាកត្តារួមចំណែកដ៏សំខាន់មួយក្នុងការបន្តប្រព្រឹត្តនូវអំពើខុសច្បាប់ និងឧក្រិដ្ឋកម្មដ៏សាហាវទាំងនេះ។ ក្នុងនាមជាជនរងគ្រោះមួយរូបក្រោមរបបខ្មែរក្រហមនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ខ្ញុំបានភៀសខ្លួនពីប្រទេសកម្ពុជា ជាមួយសមាជិកនៃក្រុមគ្រួសាររបស់ខ្ញុំដែលនៅរស់រានមានជីវិត ហើយបានរស់នៅក្នុងដំរុំជនភៀសខ្លួននៅក្នុងប្រទេសថៃជាច្រើនឆ្នាំ។ ការស្វែងសិទ្ធិជ្រកកោនដោយជោគជ័យក្នុងប្រទេសថៃ ខ្ញុំឃើញថា វាកាន់តែមានក្តីទុក្ខក្រៀមក្រំពេលឃើញប្រជាពលរដ្ឋខ្មែរត្រូវបានសម្លាប់នៅក្នុងប្រទេសថៃ ជាមួយនឹងនិទណ្ឌភាពបែបនោះនៅក្នុងសតវត្សរ៍ទី២១នេះ។

ដូច្នេះ នេះគឺជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលថៃ និងគណៈកម្មការជាតិទទួលបន្ទុកសិទ្ធិមនុស្សនៃប្រទេសថៃ ដើម្បីធ្វើការស៊ើបអង្កេតមួយដោយហ្មត់ចត់ ជាបន្ទាន់ និងប្រកបដោយភាពមិន

លម្អៀងលើករណីបាញ់ប្រហារទាំងអស់ចំពោះជនស៊ីវិលកម្ពុជា និងរាល់ករណីសង្ស័យពីឃាតកម្មក្រៅប្រព័ន្ធតុលាការ ឬការសម្លាប់តាមអំពើចិត្តក្នុងទឹកដីប្រទេសថៃ។ ការស៊ើបអង្កេតនោះ ចាំបាច់ត្រូវតែហ្មត់ចត់ ប្រកបដោយប្រសិទ្ធភាព ឯករាជ្យ ភ្លាមៗ និងដោយប្រញាប់ប្រញាល់ ហើយនីតិវិធីច្បាប់ដ៏ត្រឹមត្រូវចាំបាច់ត្រូវតែអនុវត្តតាម ដើម្បីបង្ហាញថា ប្រទេសថៃកំពុងប្រកាន់ខ្ជាប់នីតិរដ្ឋ និងថាយុត្តិធម៌នៅក្នុងប្រទេសថៃមានន័យសំខាន់ជាងការបម្រើផលប្រយោជន៍របស់អ្នកដែលខ្លាំងជាង។ លទ្ធផលនៃការស៊ើបអង្កេតគួរតែជាស្ថិតក្រោមការពិនិត្យពិច័យជាសាធារណៈ ហើយជនរងគ្រោះ ក្រុមគ្រួសារ ព្រមទាំងអ្នកតំណាងរបស់ពួកគេ គួរតែត្រូវបានជូនដំណឹងពីដំណើរការនៃការស៊ើបអង្កេត និងលទ្ធផលនៃការស៊ើបអង្កេត។ ជាចុងក្រោយ នៅពេលអនាគតប្រជាពលរដ្ឋខ្មែរណាដែលកាប់ឈើនៅតាមព្រំដែនកម្ពុជា-ថៃ ដែលមិនទាន់បានកំណត់ច្បាស់លាស់គួរតែត្រូវបានចាប់ខ្លួន ហើយកាត់ទោសតាមនីតិវិធីតុលាការដ៏ត្រឹមត្រូវ ជាជាងការផ្តាច់ផ្តិលជីវិតនៅនឹងកន្លែង។

ការរំលោភបំពានផ្នែកសិទ្ធិមនុស្សបែបនោះ បានបន្តកើតមានអស់រយៈពេលជាច្រើនឆ្នាំមកហើយ ប៉ុន្តែស្ថានភាពនេះហាក់ដូចជាកាន់តែអាក្រក់ទៅៗនាពេលថ្មីៗនេះ។ យ៉ាងណាក្តីម.ស.ម.ក សង្ឃឹមថា នៅក្នុងរយៈពេលនៃទំនាក់ទំនងកាន់តែល្អរវាងកម្ពុជា-ថៃ បញ្ហានេះ ក៏ដូចជាជម្លោះពាក់ព័ន្ធនឹងព្រំដែន អាចនឹងត្រូវបានដោះស្រាយដោយសន្តិវិធី និងស្របតាមច្បាប់អន្តរជាតិ និងគោលការណ៍សិទ្ធិមនុស្ស។ លទ្ធផលសរុបមក នឹងធ្វើឲ្យទំនាក់ទំនងផ្នែកនយោបាយ សេដ្ឋកិច្ច និងផ្នែកសង្គមកាន់តែរឹងមាំថែមទៀតរវាងប្រទេសទាំងពីរ។

សូមលោកជំទាវនាយករដ្ឋមន្ត្រីទទួលនូវគោរវៈដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣
ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

អ៊ូ ទីរៈ

ចម្លងជូន៖

- គណៈកម្មការជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សរបស់ប្រទេសថៃ
- ឯកឧត្តម ទូឆៃយុទ្ធ ជាក់ឌី ឯកអគ្គរាជទូតប្រទេសថៃ ប្រចាំកម្ពុជា

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ហោ ណាំហុង រដ្ឋមន្ត្រីការបរទេសនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ឱម យិនទៀង ប្រធានគណៈកម្មការសិទ្ធិមនុស្សកម្ពុជា
- អ្នករាយការណ៍ពិសេសរបស់ អ.ស.ប លើការកាត់ទោសក្រៅប្រព័ន្ធតុលាការ ការសម្លាប់ដោយខុសច្បាប់ ឬតាមអំពើចិត្ត

ព័ត៌មានបន្ថែមសូមទាក់ទង៖

ទូរស័ព្ទលេខ៖ +៨៥៥ (០)១២ ៤០៤ ០៥១

អ៊ីម៉ែល៖ ouvirak@cchrcambodia.org